# តន្ត្រីនិងជីវិតខ្មែរ

បណ្ឌិត កែវ ណារុំ



# VI.តន្ត្រីក្នុងពិធីសំរាប់យុវជន

## ក-សំរាប់យុវតី : ពិធីចូលម្លប់ និង ចេញម្លប់

ពិធីចូលម្លប់ និង ចេញម្លប់នេះ នៅសម័យដើមចាត់ថាជាមង្គលមួយយ៉ាងធំដែរសំរាប់ស្ត្រីខ្មែរ ។ បុព្វបុរសខ្មែរបង្កើតពិធីនេះ សំរាប់ឱ្យកូនស្រីចាប់អារម្មណ៍ពីលំដាប់ថ្នាក់ប្រចាំជីវិត ដែលត្រូវឈានឡើងដោយឱ្យប្រឹងប្រែងតស៊ូជានិច្ចដើម្បីវឌ្ឍនភាព ។ ថ្វីត្បិតតែខ្មែរជំនាន់ក្រោយមិនឱ្យន័យ បានបោះបង់ចោលទំនៀមទំលាប់នេះ ដែលលែងសមស្របនឹងសម័យកាលឥឡូវក៏ពិតមែន ។ ជាការសោកស្តាយបំផុត ដែលសព្វថ្ងៃនៅព្រះរាជាណាចក្រកម្ពុជាយើង ពិធីនេះ*(ឬជាព្រលឹង)* កំពុងទ្រុឌទ្រោម ហើយអាចរលត់សាបសូន្យបានក្នុងពេលអនាគតយ៉ាងខ្លីខាងមុខនេះ ។ ម៉្យាងទៀតខ្មែរនៅស្រុកសៀម ឬ នៅកម្ពុជាក្រោម ក៏ស្ថិតនៅក្នុងស្ថានភាពដូចគ្នាដែរ ។

ឆ្លងពីថ្នាក់កុមារីចូលដល់វ័យពេញក្រមុំ ការកំណត់របស់សង្គមខ្មែរស្ថិតនៅត្រង់ការមករដូវជាលើកទីមួយ ដែលគេនិយមហៅថា«**គ្រប់ការ**» ។ សំរាប់ថ្នាក់នេះនៅពេលកំពុងឈានឡើង នាងមានលក្ខណៈប្លែក គឺអត្តចរិតជូនឆាប់ខឹងជូនអៀនខ្មាស់ ជូនចូលចិត្តស្ងប់ស្ងាត់នៅតែម្នាក់ឯង ឬ ព្រួយចិត្តដោយឥតមូលហេតុ ។ នាងនឹងមានការភិតភ័យណាស់ ប្រសិនបើពុំមាននរណាម្នាក់បានពន្យល់ប្រាប់ជាមុន ពីហេតុការណ៍ធម្មជាតិ ដែលនឹងត្រូវកើតមានឡើងចំពោះនាង ។ នាទីនេះគឺអ្នកម្តាយតែងឃ្លាំមើលឥរិយាបថរបស់កូនស្រី ដើម្បីពន្យល់និងជួយរៀបចំគ្រឿងស្លៀកពាក់ផ្សេងៗសំរាប់កូន ។ មិនចំពោះតែអ្នកម្តាយទេ គឺក្នុងគ្រួសារទាំងមូលដែលត្រូវជួយជ្រោមជ្រែងទាំងផ្លូវកាយរហូតដល់ផ្លូវចិត្ត និង ប្រាជ្ញា ដើម្បីឱ្យនាង

មានសមត្ថភាពគ្រប់គ្រាន់សំរាប់ពេលខាងមុខ ។ នាងនឹងត្រូវបំពេញតួនាទីជាភរិយា ហើយនឹងជាម្តាយដ៏ល្អសំរាប់សង្គម ។ ភារកិច្ចជាភរិយានិងជាម្តាយនេះ មានទំហំធំធេងណាស់ អាចកំណត់ន័យជីវិតរបស់ស្ត្រីខ្មែរគ្រប់រូប ។ ហេតុដូច្នេះហើយ បានជាលោកបង្កើតពិធីនេះឡើង ដើម្បីធ្វើការបំពាក់បំប៉នស្ត្រីខ្មែរជាមុន ៗនឹងឈាន ទៅបំពេញតួនាទីដ៏ចំបងនេះ ។

**១.<u>ពិធីចូលម្លប់</u>** : គេបញ្ចូលម្លប់កូនស្រីមិនមើលពេលាទេ ។គឺសំរេចយកថ្ងៃណាមួយដែលនាងមករដូវជាលើកទីមួយ ។ ចំណែកពិធីក៏មិនមានរៀបចំអ្វីធំដុំទេ គឺគ្រាន់តែម្តាយឪពុកនាងជំរាបដល់សាច់ញាតិជិតជិតឱ្យបានដឹងថា កូនស្រីឈ្មោះនេះ បានបញ្ចូលម្លប់នៅថ្ងៃនេះថ្ងៃនោះហើយ ។ នៅថ្ងៃបញ្ចូល គេរៀបសែនព្រេនអុជធូបទៀនជំរាបជូនតា និង ប្រកាសចំពោះវត្ថុសក្តិសិទ្ធិឱ្យបានដឹងឮ អំពីការចូលម្លប់របស់កូនស្រី និង សុំសេចក្តីសុខសប្បាយ ។ ប្រការសំខាន់គឺត្រូវគិតគូរពីអ្នកជួយបំរើ សេចក្តីត្រូវការរបស់នាង និង ជួយប៉ណ្តុះបណ្តាលនាង ។ ប្រការសំខាន់មួយទៀត គឺត្រូវត្រៀមលក្ខណៈសំរាប់ថ្ងៃបញ្ចេញម្លប់ ដោយមានបំរុងគ្រឿងហូបចុក សំរាប់ភ្ញៀវដែលត្រូវមកចូលរួមក្នុងពិធី ។ ការត្រៀមលក្ខណៈនេះស្រុកខ្លះគេដាំចេកណាំវ៉ាជានិមិត្តរូប គឺប្រារព្ធពិធីបញ្ចេញម្លប់នៅពេលផ្លែចេកទុំ ។ ខ្លះទៀតគេចិញ្ចឹមមាន់ទាជាដើម តាមលទ្ធភាពក្នុងគ្រួសារ ។ ពេលវេលានៃការចូលម្លប់មិនមានកំណត់ទេ គឺយោលតាមធនធាននៃគ្រួសារ អ្នកខ្លះចូលក្នុងរយៈពេលមួយសប្តាហ៍ ខ្លះចូលរហូតដល់មួយឆ្នាំក៏មានដែរ ។

**<u>ភារកិច្ចក្នុងពេលចូលម្លប់</u>** : ពេលចូលម្លប់ គឺជាពេលដែលកូនស្រីខ្មែរត្រូវបានទទួលការសិក្សា ពីក្បួនច្បាប់ទូន្មានដ៏ល្អៗជាច្រើន ពិសេសច្បាប់ទូន្មានសំរាប់ស្ត្រី ។ ច្បាប់នេះចែងពីតួនាទីរបស់ស្ត្រីក្នុងការរស់នៅ ។ លោកបានចែងថា សេចក្តីសុខនិងសុភមង្គលក្នុងគ្រួសារមួយភាគធំ ស្ថិតនៅលើស្ត្រីជាអ្នកកំណត់ ។ ដូច្នេះគេត្រូវឱ្យនាងទន្ទេញឱ្យចាំស្ទាត់ ដើម្បីទុកអនុវត្តតាមលំអានដែលក្បួនបាន

ចែង ។ ក្រៅពីសិក្សាក្បួនច្បាប់ នាងត្រូវរៀនធម៌ ។ ប្រសិនបើសុខភាពនាងធានា នាងត្រូវកាន់សីល១០ ដើម្បីកាន់ចិត្តអំណត់ខន្តីដូចដូនជីដែរ ។ ក្នុងជីវភាពជាដូនជី នាងត្រូវហូបចុកម្ហូបបួស ហើយកំណត់តាមពេលម៉ោងដូចព្រះសង្ឃដែរ ។ នាងមានតំណមលើសដូនជី ដោយមិនត្រឹមតែមិនឱ្យប្រុសៗឃើញប៉ុណ្ណោះទេ គឺមិនអនុញ្ញាតឱ្យនិយាយឆ្លើយឆ្លងរកបុរសទៀត ។ នាងត្រូវតស៊ូសំងំនៅតែក្នុងបន្ទប់ពិសេសមួយ ដើម្បីចាំត្រងស្ដាប់នូវវិជ្ជាមេផ្ទះស្ដីពីការរស់នៅក្នុងគ្រួសារចំពោះសាច់ញាតិផ្ទាល់ ឬ ញាតិជិតខាង ពិសេសអាកប្បកិរិយាចំពោះប្ដីនិងគ្រួសារប្ដី ។ ជាមួយគ្នានោះ ក៏ត្រូវរៀនពីវិជ្ជាធ្វើម្ហូប វិជ្ជាតំបាញ ការរៀបចំផ្ទះសំបែង និង ការអប់រំកូនចៅជាដើម ។ ភារកិច្ចម៉្យាងទៀតត្រូវថែទាំសាច់ ដោយត្រូវលាបរមៀតសព្វខ្លួនប្រាណដៃជើង ឱ្យមានសម្បុរលឿងល្អស្រស់ផ្ទូរផង់ ។

**២_<u>ពិធីចេញម្លប់</u>** : ពិធីចេញម្លប់ មានលក្ខណៈជាពិធីច្រើនយ៉ាងខុសពីពិធីចូលម្លប់ ។ ប៉ុន្តែវត្ថុបំណងគឺ **ការបំពេញលក្ខណ៍គំរប់ឱ្យកូនស្រី** ។

ឆ្លងរយៈកាលបញ្ចូលម្លប់គ្រប់តាមការកំណត់ហើយ មាតាបិតានៃសាមីខ្លួនដែលកំពុងនៅក្នុងម្លប់នោះ បានទៅរកអាចារ្យដើម្បីបីសរកពេលាល្អ កំណត់ថ្ងៃប្រារព្ធពិធីបញ្ចេញម្លប់កូន ។ ពេលដឹងថ្ងៃជោគសិរីមង្គលហើយ ក្នុងគ្រួសារទាំងអស់មមាញឹកដើររកភស្តុភារ និង ជំរាបអញ្ជើញញាតិមិត្តដូចការរៀបមង្គលការដែរ ។

កម្មវិធីនៃដំណើរការពិធី មានរយៈពេលពីរថ្ងៃមួយយប់ ។ ប៉ុន្តែមុននឹងចូលដល់ថ្ងៃដំណើរការពិធីមួយថ្ងៃមុន គេត្រូវចាត់ចែងធ្វើនំគ្រប់មុខ និង ត្រៀមផ្លែឈើដើម្បីទុកជូនញាតិពិសា ។ ថ្ងៃជាមួយគ្នានោះដែរ គេត្រូវសង់រោងសំរាប់រៀបចំជប់លៀងភ្ញៀវ ដែលគេហៅថាថ្ងៃ«**ចូលរោង**» ។

នៅថ្ងៃដំណើរការដំបូង ចាប់ពីពេលព្រឹករហូតថ្ងៃត្រង់ មានតែការទទួលសាច់ញាតិជិតខាង និង ការលៀងភោជនាហារតែប៉ុណ្ណោះ ។ ប៉ុន្តែចាប់ពីពេលរសៀលទៅ មានពិធីជាហូរហែបន្តបន្ទាប់ដូចតទៅ ÷

**២.១.<u>ពិធីកាត់សក់</u>** : ឱកាសនេះគឺជាលើកដំបូងហើយ ដែលគេត្រូវបញ្ចេញកូនស្រីដើម្បីមកកាត់សក់ ។ ប៉ុន្តែនាងត្រូវចេញមកនៅត្រឹមក្នុងផ្ទះដដែលទេ ពាន សេចក្តីថាទើបតែអាចចេញពីបន្ទប់ ដែលនាងបានគស្ងៀរស់នៅក្នុងនោះមួយរយៈពេលកន្លងមកហើយ ។ បន្ទាប់ពីកាត់សក់លាបប្រេងម្សៅហើយ នាងត្រូវវិលចូលទៅក្នុងបន្ទប់វិញ ។ នៅពេលកាត់សក់ ភ្លេងលេងកំដរឡូវ **បទសារិកាកែវ** ។

**២.២.<u>ពិធីសូត្រមន្ត</u>** : បន្ទាប់ពីរៀបចំជូនភ្ញៀវពិសាភោជនាហារថ្ងៃត្រង់ ដោយមានភ្លេងប្រពៃណីកំដរបរិយាកាសផងនោះ គឺថ្ងៃរសៀលគេត្រូវរៀបចំពិធីសូត្រមន្ត ។ សាច់ញាតិជាស្ត្រីភេទម្នាក់ ដែលគេទទួលស្គាល់ថាខ្ពង់ខ្ពស់ មានចរិយាសម្បត្តិល្អ ត្រូវទៅបន្ទប់ដឹកដៃនាងឱ្យចេញមកទទួលទឹកមន្ត និង ធម៌លើកភាសីពីព្រះសង្ឃ ។

**២.៣.<u>ពិធីសែនព្រេន</u>** : នៅពេលព្រលប់ គេមានរៀបពិធីសែនព្រេនជូនដូនតា ម្ចាស់ទឹកដីក្នុងភូមិ ដើម្បីជំរាបអស់លោក និង សុំសេចក្តីសុខសប្បាយ ។ ភ្លេងលេងកំដរ **បទកងសោយ** ។

**២.៤.<u>ពិធីបុកល័ក្ខ</u>** : ពិធីនេះគេធ្វើនៅវេលាយប់ បន្ទាប់ពីការពិសាភោជនាហារហើយ ដែលប្រកបដោយពិធីជាហូរហែបន្តបន្ទាប់ទៀតគឺ ÷

**២.៤.១.<u>ពិធីទៅរកល័ក្ខ</u>** : ពិធីនេះជាដំណើរការដោយសារអ្នកភ្លេង គឺជារបៀបលេងសើចកំប្លុកកំប្លែង ។ នៅពេលទៅរកល័ក្ខក្នុងព្រៃ គេបានជួបសត្វតានិដេញចិចស្មុះច្រឡោតជាន់គ្នារញ៉េរញ៉ៃ ។ ឆាកនេះបានផ្តល់ឱ្យបរិយាកាសរីករាយសប្បាយដល់ភ្ញៀវ គ្រាន់លេងកំសាន្តកែអផ្សុក ក៏ដូចជាការឧបកិច្ចទៅរកល័ក្ខក្នុងព្រៃ ។ បន្ទាប់ពីបានល័ក្ខហើយ គេយកទៅទុកមួយកន្លែងសិន ។ ភ្លេងលេងកំដរពិធីនេះគឺ **បទអុំទូក** ។

**២.៤.២.ពិធីកាត់ត្បាល់** : ពិធីនេះក៏ដំណើរការដោយសារអ្នកភ្លេងដែរ គឺគេធ្វើកាយវិការចូលទៅក្នុងព្រៃរើសយកឈើល្អ ឬ ឈើដែលគេមានជំនឿថា មានសិរីមង្គល ដើម្បីកាប់យកមកធ្វើត្បាល់ ។ បានជាត្រូវមានរៀបពិធីនេះ ព្រោះគេត្រូវយកត្បាល់ថ្មីមិនទាន់ប្រើឱ្យសមស្របតាមសាមីខ្លួន ដែលទើបចេញពីម្លប់ ។ ក្នុងពេលនោះអ្នកភ្លេងត្រូវលេង **បទសុរិន្ទ្រ** ឬ **អង្គររាជ** ។ គេច្រៀងរៀបរាប់ពីទឹកដីនៃខេត្តទាំងពីរនេះ ដែលសំបូរទៅដោយព្រៃឈើ ហើយដើម្បីរំលឹកពីអតីតមរតករបស់ខ្មែរ ដែលសព្វថ្ងៃស្ថិតនៅប្រទេសសៀម ។

**២.៤.៣.ពិធីបុកល័ក្ខ** : ពិធីនេះប្រារព្ធឡើងដើម្បីយកល័ក្ខ មកធ្វើធ្មេញបំពេញល័ក្ខឱ្យកូនស្រី ។ គេឱ្យកុមារីព្រហ្មចារីយ៍បួននាក់ មកបកក្រមរល័ក្ខចេញពីមែកឈើ រួចប្រគល់ជូនទៅលោកអាចារ្យ ។ លោកអាចារ្យទទួលយកល័ក្ខក្រមរនោះ ទៅដាក់ក្នុងត្បាល់ដោយធ្វើកិច្ចសូត្រគាថាប្រសិទ្ធពរជ័យ ។ បន្ទាប់មកអ្នកភ្លេងជាអ្នកដើរតួបុកល័ក្ខ ប្រកបដោយកាយវិការចាក់ក្បាច់រាំតាមចង្វាក់ភ្លេង ។ គេបុកផងច្រៀងរាំផង រហូតទាល់តែល្អិតទើបកាយដាក់ផ្តិល ប្រគល់ជូនទៅលោកអាចារ្យ ។ ភ្លេងលេងកំដរនូវ **បទជៀសស្រូវ** ។

**២.៥.ពិធីធ្វើធ្មេញ** : អាចារ្យទទួលយកល័ក្ខពីអ្នកភ្លេង ហើយត្រូវយកទៅដាំស្ងោរ នៅចំកណ្តាលផ្ទះជាមួយសំបកស្បែង និង ផ្លែសំបួរមាស ។ គេដាក់ដាំដោយឆ្នាំងថ្មី និង ចង្ក្រានថ្មីដែរ ដោយរំងាស់ឱ្យចេញជាតិឡើងក្រហមស្រស់ បានយកទៅឱ្យសាមីខ្លួនបៀម ។ មានអ្នកខ្លះ យកផ្ទៃចបជីកថ្មីមួយដែលបានលាងទឹក ហើយយកទៅគងពីលើឆ្នាំងស្ងោរល័ក្ខ ដើម្បីទទួលចំហាយទឹកល័ក្ខដែលពុះគគ្រុក ។ នៅពេលមានចំហាយទឹក អាចារ្យយកសំឡីទៅផ្តិតយកតំណក់ចំហាយទឹកល័ក្ខ មកលាបធ្មេញកូនស្រីចេញម្លប់ ។ ខ្លះទៀតគេយកទឹកឱ្យបៀម ឬ ផ្តិតធ្មេញតែម្តង ។ អាចារ្យតែងជូនពរមានជាអាទិថា : **សូមឱ្យឥទ្ធិពលនៃទឹកល័ក្ខនេះធ្វើឱ្យនាងក្លាយជាស្ត្រីគ្រប់លក្ខណ៍ពេញបរិបូណ៌...**។ ភ្លេងលេងកំដរនូវ**បទស្ទៅង** ។